**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ: ៣២៩២ PC.អក

# សេចក្តីជូនដំណឹង (លើកទី២)

## ស្តីពី

សេវាកម្មដឹកជញ្ជូន តម្លើង ប្រមូលប្រាក់បង់សងវិលស់ និងថែទាំប្រព័ន្ធ SHS-200Wp ចំនួន 1,850ប្រព័ន្ធ សម្រាប់ឆ្នាំ២០១៩

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តា ក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីសេវាកម្មដឹកជញ្ជូន តម្លើង ប្រមូលប្រាក់បង់សងវិលស់ និងថែទាំប្រព័ន្ធ SHS-200Wp ចំនួន 1,850ប្រព័ន្ធ សម្រាប់ឆ្នាំ២០១៩ ។

អគ្គិសនីកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋានៈ អាគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញចាប់ពី ថ្ងៃទី 08 ខែ កក្កដា ឆ្នាំ 2019 តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង 14:00 ថ្ងៃទី 24 ខែ កក្កដា ឆ្នាំ 2019 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើវេលាម៉ោង 16:30 ថ្ងៃទី 24 ខែ កក្កដា ឆ្នាំ 2019 ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។/.

ថ្ងៃ សុក្រ ៤ កើត ខែ អាសាឍ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៩

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ខៃត សុខន

ចម្លងជូន៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ